**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្ដីការក្រសួងយុត្តិធម៌**

លេខ: ២៤...គសស-ប្រក/០៥

ភ្នំពេញ, ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០៥

# ប្រកាស

## ស្ដីពីតួនាទី និងភារកិច្ចរបស់ខុទ្ទកាល័យ

## រដ្ឋមន្ត្រី ក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញក្រឹត្យលេខ ០៦.ក្រ ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្ដីនៃរដ្ឋកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- យោងតាមការចាំបាច់របស់ក្រសួងយុត្តិធម៌

## សំរេច

**ប្រការ ១ :** ខុទ្ទកាល័យក្រសួងយុត្តិធម៌ មានតួនាទី និងភារកិច្ច ដូចតទៅ :

- ទទួលបញ្ជា និងអនុវត្តតាមសេចក្ដីណែនាំផ្ទាល់ពីឯកឧត្តមរដ្ឋមន្ត្រី
- ទទួលពិនិត្យ និងរៀបចំរាល់សំណុំលិខិត ឯកសារនានា ដាក់ជូនឯកឧត្តមរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងសំរេច
- លើកសំណើ និងយោបល់ ចំពោះកិច្ចការទូទៅរបស់ក្រសួង ជូនឯកឧត្តមរដ្ឋមន្ត្រី
- ទំនាក់ទំនង និងសំរបសំរួលការងារជាមួយអង្គភាពចំណុះ និងនាយកដ្ឋានទាំងឡាយក្រោមឱវាទក្រសួង ។
- ទំនាក់ទំនងជាមួយខុទ្ទកាល័យ និងអគ្គលេខាធិការដ្ឋាន នៃក្រសួង-ស្ថាប័នជាតិនានា ព្រមទាំងអង្គការជាតិ អន្តរជាតិ និងប្រព័ន្ធឃោសនាផ្សេងៗ ។
- រៀបចំកាលវិភាគជូនឯកឧត្តមរដ្ឋមន្ត្រី ឱ្យមានដំណើរការល្អប្រសើរ ។

- ចូលរួមក្នុងរាល់កិច្ចប្រជុំនានា សន្និបាត សន្និសីទ សិក្ខាសាលា និងពិធីផ្សេងៗ ដើម្បីប្រមូលពត៌មានជូនឯកឧត្តមរដ្ឋមន្ត្រី ។
- បញ្ជូន និងផ្សព្វផ្សាយ បទបញ្ជា ការណែនាំ របស់ឯកឧត្តមរដ្ឋមន្ត្រី ដល់អង្គភាពចំណុះ និងនាយកដ្ឋានទាំងឡាយក្រោមឱវាទក្រសួង ព្រមទាំងតាមដានការអនុវត្តនីបទបញ្ជា និះការណែនាំទាំងនោះ ដើម្បីជំរុញការងារឱ្យមានប្រសិទ្ធភាព ។
- បំពេញការងារផ្សេងៗទៀត តាមការប្រគល់ភារកិច្ចពី ឯកឧត្តមរដ្ឋមន្ត្រី ។

**ប្រការ ២ :** នាយកខុទ្ទកាល័យដឹកនាំរួម និងមាននាយខុទ្ទកាល័យ ជំនួយការ និងលេខាធិការមួយចំនួនតាមការចាំបាច់ជាជំនួយ ។

**ប្រការ ៣ :** ខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គាធិការដ្ឋានកិច្ចការតុលាការ, គ្រប់នាយកដ្ឋានចំណុះក្រសួងយុត្តិធម៌, តុលាការ និងអយ្យការអម តុលាការខេត្ត ក្រុង និងសាមីខ្លួន មានភារកិច្ចអនុវត្តនូវសេចក្តីប្រកាសនេះ ឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

រដ្ឋមន្ត្រី

[illegible]

ចម្លងជូន:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ដូចប្រការ ៣

"ដើម្បីជូនជ្រាប និងអនុវត្ត"
- ឯកសារ-កាលប្បវត្តិ